ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..៦០៧........អបស.ហ.ជ.ម

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០០៥

# ប្រកាស

## ស្តីពី

## ការដាក់អោយអនុវត្តនូវកម្មវិធីសិក្សាគិលានុបដ្ឋាក-ឆ្មប បឋម

***

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខ ១១៩៨/៧២ នស/រកត/ចុះថ្ងៃទី ៣០-១១-៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០១៩៦ / ០៦ នស / រកម ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រិត្យលេខ ៦៧ អនក្រ. បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រិត្យលេខ ១២៩ អនក្រ. បក ចុះថ្ងៃទី ៣០- ១២- ២០០២ ស្តីពីការគ្រប់គ្រងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ
- បានឃើញប្រកាសលេខ៣១១សនប ចុះថ្ងៃទី២៨-០៥-២០០៣ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១**-ដាក់អោយអនុវត្តនូវកម្មវិធីសិក្សាគិលានុបដ្ឋាក-ឆ្មបបឋម ដែលមានរយៈពេលមួយឆ្នាំនៅតាមសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ បាត់ដំបង កំពង់ចាម កំពត រ៉ែង ស្ទឹងត្រែង ចាប់ពីឆ្នាំសិក្សា ២០០៥-២០០៦ នេះតទៅ។

**ប្រការ ២**-សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគនីមួយៗ ត្រូវទទួលខុសត្រូវគ្រប់គ្រង និង បណ្តុះបណ្តាលសិស្សមកពីខេត្តដូចខាងក្រោមៈ

១- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគបាត់ដំបង

- ខេត្ត បាត់ដំបង
- ក្រុង ប៉ៃលិន
- ខេត្ត បន្ទាយមានជ័យ
- ខេត្ត ឧត្តរមានជ័យ
- ខេត្ត សៀមរាប
- ខេត្ត ពោធិសាត់
- ខេត្ត កំពង់ឆ្នាំង



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល,លេខ ១៥១-១៥៣ វិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៤/៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៨៣៣

២- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម

- ខេត្ត កំពង់ចាម
- ខេត្ត កំពង់ធំ
- ខេត្ត ព្រៃវែង
- ខេត្ត ស្វាយរៀង
- រាជធានី ភ្នំពេញ
- ខេត្ត កណ្ដាល

៣- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពត

- ខេត្ត កំពត
- ក្រុង កែប
- ក្រុង កំពង់សោម
- ខេត្ត កោះកុង
- ខេត្ត តាកែវ
- ខេត្ត កំពង់ស្ពឺ

៤- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង

- ខេត្ត ស្ទឹងត្រែង
- ខេត្ត រតនៈគិរី
- ខេត្ត មណ្ឌលគិរី
- ខេត្ត ព្រះវិហារ
- ខេត្ត ក្រចេះ

**ប្រការ ៣**.-សិស្សដែលបានប្រឡងបញ្ចប់ការសិក្សា វគ្គគិលានុបដ្ឋាក-ឆ្មប បឋម ដោយជោគជ័យ ត្រូវបានទទួលសញ្ញាប័ត្រ ជាគិលានុបដ្ឋាកបឋម ឬ ឆ្មបបឋម ដែលចេញដោយក្រសួងសុខាភិបាល ។

**ប្រការ ៤**.- នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សមានភារៈកិច្ច អភិបាល តាមដាន និង វាយតំលៃ លើការអនុវត្តន៍កម្មវិធីបណ្តុះបណ្តាលគិលានុបដ្ឋាក-ឆ្មប បឋម នៅតាមសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ នីមួយៗ ដោយមានការចូលរួមសហការណ៍ពីសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ពាក់ព័ន្ធ ។

**ប្រការ ៥**.- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ បាត់ដំបង កំពង់ចាម កំពត និង ស្ទឹងត្រែង មានភារៈកិច្ច អនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ៦** - ប្រកាសទាំងឡាយណាដែលមានខ្លឹមសារខុសពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. នុត_សុខុម

<u>ចំលងជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ពាក់ពន្ធ័
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- ដូចប្រការ ៥
- ឯកសារ
- កាលប្បវត្តិ